**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលារាជធានីភ្នំពេញ**

# សេចក្តីប្រកាសព័ត៌មាន

សាលារាជធានីភ្នំពេញ សូមជម្រាបជូនដំណឹងដល់សាធារណជនមេត្តាជ្រាបថា នៅព្រឹកថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៤ វេលាម៉ោង ០៧:៣០នាទី មានប្រជាពលរដ្ឋតំបន់បឹងកក់ប្រមាណ ៤០នាក់ បានប្រមូលផ្តុំគ្នានៅមុខសាលារាជធានីភ្នំពេញ ក្នុងគោលបំណងស្នើសុំឱ្យមានការដោះស្រាយបញ្ហាទឹកលិចតំបន់បឹងកក់។ សាលារាជធានីភ្នំពេញ បានទទួលយកសំណូមពររបស់ពួកគាត់ ដើម្បីបន្តការដោះស្រាយ ព្រោះថា កន្លងមកអាជ្ញាធរពុំដែលព្រងើយកន្តើយចំពោះបញ្ហាខាងលើនេះ ដោយមានចំណាត់ការជាបន្តបន្ទាប់ក្នុងការរំដោះទឹកចេញពីតំបន់នេះផងដែរ។

ប្រការដែលគួរឱ្យសោកស្តាយនោះគឺ ពួកគាត់បានធ្វើការតវ៉ាដោយប្រាសចាកពីគោលបំណងដើមរបស់ខ្លួន ដោយបានប្រើប្រាស់សម្ភារៈមួយចំនួនមកបិទច្រកចេញចូលសាលារាជធានីភ្នំពេញ និងបានប្រមូលផ្តុំគ្នាអង្គុយបិទផ្លូវមហាវិថីព្រះមុនីវង្ស បង្កឱ្យមានការកកស្ទះចរាចរណ៍ ដែលធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់អ្នកដំណើរឆ្លងកាត់។ ទង្វើនេះ គឺបានប្រាសចាកពីមាត្រាទី៧៨ នៃច្បាប់ស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក និងការសម្តែងមតិដោយសន្តិវិធី។

ដើម្បីសម្រួល និងបើកចរាចរណ៍ឡើងវិញ អាជ្ញាធរមានសមត្ថកិច្ចបានព្យាយាមប្រកាសផ្សព្វផ្សាយណែនាំតាមប្រព័ន្ធឃោសនសព្ទជាច្រើនលើកច្រើនសារ ឱ្យអ្នកតវ៉ាទាំងអស់ធ្វើការបើកផ្លូវ ប៉ុន្តែពួកគាត់នៅតែចចេសរឹងរូស ដោយពុំស្តាប់តាមការណែនាំរបស់អាជ្ញាធរមានសមត្ថកិច្ចឡើយ។ ក្នុងគោលបំណងរក្សាសណ្តាប់ធ្នាប់ និងផលប្រយោជន៍សាធារណៈរបស់ប្រជាពលរដ្ឋទូទៅ អាជ្ញាធរមានសមត្ថកិច្ចបានបង្ខំចិត្តចាត់វិធានការតាមផ្លូវច្បាប់ចំពោះអ្នកមិនអនុវត្តតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

អាស្រ័យហេតុនេះ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន។

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៤

**សាលារាជធានីភ្នំពេញ**